ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ភ្នំពេញ ថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០០៦

# សេចក្តីជូនដំណឹង

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** មានកិត្តិយសសូមជំរាបជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋខ្មែរទាំងអស់មេត្តាជ្រាបថា :

១-ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ២០០៦ សំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២ ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៧ នឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ ២០០៦ ខាងមុខនេះ ។

២-លិខិតធានាអះអាងពីអត្តសញ្ញាណ ឬ/និងអាយុនៃអ្នកសុំចុះឈ្មោះបោះឆ្នោត និងការបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ មានបិទរូបថត ( ទម្រង់បែបបទលេខ១០១៨ របស់ គ.ជ.ប ) ដែលចេញដោយមេឃុំ ចៅសង្កាត់ ជូនប្រជាពលរដ្ឋដើម្បីប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោតកន្លងមក នៅតែមានសុពលភាព សំរាប់ការប្រើប្រាស់តទៅទៀត ។

៣-ប្រជាពលរដ្ឋដែលពុំទាន់បានចុះឈ្មោះបោះឆ្នោត ពិសេសយុវជន យុវនារីដែលទើបគ្រប់អាយុបោះឆ្នោត គឺអាយុគ្រប់១៨ឆ្នាំគិតដល់ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៧ និងដែលពុំទាន់មានឯកសារសម្រាប់បញ្ជាក់អត្តសញ្ញាណ អាយុ និងទីលំនៅក្នុងឃុំ សង្កាត់ សូមអញ្ជើញទៅជួបមេឃុំ ចៅសង្កាត់ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ដើម្បីស្នើសុំលិខិតធានាអះអាងពីអត្តសញ្ញាណ ឬ/និងអាយុនៃអ្នកសុំចុះឈ្មោះបោះឆ្នោត និងការបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ( ទម្រង់បែបបទលេខ ១០១៨ របស់ គ.ជ.ប) ដើម្បីប្រើប្រាស់សំរាប់ការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត ។ សូមនាំទៅជាមួយផងនូវសាក្សីចំនួនពីរ(២)រូប ដែលជាអ្នកមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់ និងរូបថតសាមីខ្លួនចំនួនពីរ (២)សន្លឹក ។

សេចក្តីដូចខាងលើនេះក៏សូមជំរាបជូនដល់អាជ្ញាធរមានសមត្ថកិច្ច ក្រុមប្រឹក្សាឃុំ សង្កាត់ គណបក្សនយោបាយ និងអង្គការសង្កេតការណ៍បោះឆ្នោតដើម្បីអនុវត្ត និងរួមសហការ ។

**សូមអរគុណ**